**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៦១/ ០១/ ២០១៨

ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨

## សូមក្រាបបង្គំទូលថ្វាយ
## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

**<u>កម្មវត្ថុ</u>:** សេចក្តីទូលថ្វាយមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

**<u>យោង</u>:** ព្រះរាជសារចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨

ទូលព្រះបង្គំយើងខ្ញុំ ជាប្រធាននិងសមាជិកសមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលព្រះរាជសារដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ ហើយបានអនុម័តដោយចំនួន ៨ សំឡេងនៃចំនួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល (អវត្តមាន ០១អង្គ ដោយមូលហេតុប្រឈួន)។ ទូលព្រះបង្គំយើងខ្ញុំសូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមទ្រង់ព្រះមេត្តាជ្រាបដូចតទៅ÷**

១-ការផ្តួចផ្តើមគំនិតធ្វើវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺស្របតាមបរិបទនៃការវិវត្តរីកចម្រើនរបស់សង្គម និងសភាពការណ៍ជាក់ស្តែង ពុំមានអ្វីប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញឡើយ ព្រមទាំងធ្វើឡើងនៅក្នុង

កាលៈទេសៈធម្មតារបស់ប្រទេសជាតិថែមទៀតផង ដោយផ្អែកលើមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញដូចខាងក្រោម ÷

មាត្រា១៥៣ថ្មី (ពីរ មាត្រា១៥១ថ្មី) នៃរដ្ឋធម្មនុញ្ញ ចែងថា “ *ការផ្ដើមគំនិតសើរើ ឬ ការផ្ដើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និង របស់ប្រធានរដ្ឋសភា តាមសេចក្ដីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។*

*ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។* ”

មាត្រា១៥៤ថ្មី (ពីរ មាត្រា១៥២ថ្មី) នៃរដ្ឋធម្មនុញ្ញ ចែងថា “ *ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា៨៦។* ”

មាត្រា១៥៥ថ្មី (ពីរ មាត្រា១៥៣ថ្មី) នៃរដ្ឋធម្មនុញ្ញ ចែងថា “ *ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ។* ”

២-ក្រុមប្រឹក្សាធម្មនុញ្ញ យល់ឃើញថា សេចក្ដីព្រាងច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្ម មាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើទៅបាន។

**សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំ។**

ថ្ងៃពុធ ០៧ រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**អ៊ឹម ឈុនលឹម**